ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ....១០៨៥៦....អពដ

L202207190562 | TD2038

ថ្ងៃ ១១កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២២

# សេចក្ដីណែនាំ
## ស្ដីពី
## ការដាក់ឱ្យអនុវត្តមុខងារស្នើសុំឥណទានពន្ធ ក្នុងប្រព័ន្ធគ្រប់គ្រងការស្នើសុំចៀសវាងការយកពន្ធត្រួតគ្នាតាមអនឡាញ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ឱ្យបានជ្រាបថា អនុវត្តតាមសេចក្ដីណែនាំលេខ ៤០៨៤ អពដ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ ស្ដីពីវិធាន និងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេសពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ( Double Taxation Agreement-DTA ) ជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានដាក់ឱ្យប្រើប្រាស់រួចមកហើយ នូវប្រព័ន្ធគ្រប់គ្រងការស្នើសុំចៀសវាងការយកពន្ធត្រួតគ្នាតាមអនឡាញ។ ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបានអភិវឌ្ឍបន្ថែមនូវមុខងារស្នើសុំឥណទានពន្ធ ក្នុងប្រព័ន្ធគ្រប់គ្រងការស្នើសុំចៀសវាងការយកពន្ធត្រួតគ្នាតាមអនឡាញ ដើម្បីជួយសម្រួលដល់ការស្នើសុំ ព្រមទាំងធានាប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពផងដែរ។

ដើម្បីចូលប្រើប្រាស់មុខងារស្នើសុំឥណទានពន្ធនេះ លោក-លោកស្រី ត្រូវអនុវត្តតាមបែបបទ និងនីតិវិធី ដូចខាងក្រោម៖

### I. ការចុះឈ្មោះចូលប្រើប្រាស់ប្រព័ន្ធ

ចំពោះអ្នកប្រើប្រាស់ទាំងឡាយណាដែលពុំទាន់មានគណនី ត្រូវចុះឈ្មោះប្រើប្រាស់ប្រព័ន្ធ ដោយអនុវត្តដូចខាងក្រោម៖

១. ចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh/km/e-service
២. ចុចប៊ូតុង បង្កើតគណនីថ្មី
៣. បំពេញព័ត៌មានតាមការតម្រូវដូចមានបង្ហាញក្នុងប្រព័ន្ធ រួចចុចបន្ទាប់។

ដោយឡែកចំពោះអ្នកប្រើប្រាស់ដែលមានគណនីនិងធ្លាប់ប្រើប្រាស់ប្រព័ន្ធអនឡាញផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដាររួចហើយ មិនតម្រូវឱ្យចុះឈ្មោះប្រើប្រាស់ឡើងវិញទេ។

### II. មុខងារលម្អិតសម្រាប់ការប្រើប្រាស់ប្រព័ន្ធ

ក្នុងការប្រើប្រាស់មុខងារស្នើសុំឥណទានពន្ធ តាមរយៈប្រព័ន្ធគ្រប់គ្រងការស្នើសុំចៀសវាងការយកពន្ធត្រួតគ្នាតាមអនឡាញ អ្នកប្រើប្រាស់ត្រូវអនុវត្តនីតិវិធីលម្អិត ដូចខាងក្រោម៖

១. ចូលទៅកាន់គេហទំព័រដែលមានអាសយដ្ឋាន https://www.tax.gov.kh/km/e-service



អាគារតេជោមហាវិថី សហព័ន្ធរុស្ស៊ី ( ១១០ )និង ម៉ៅសេទុង( ២៤៥ ) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ( +855 ) 23 886 708 ទូរសារ: ( +855 )23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

២. ប្រើប្រាស់គណនីអ្នកប្រើប្រាស់ (Username) និងពាក្យសម្ងាត់ (Password) ដើម្បីចូលប្រើប្រាស់ប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

៣. ជ្រើសរើស **ប្រព័ន្ធគ្រប់គ្រងការស្នើសុំចៀសវាងការយកពន្ធត្រួតគ្នា** បន្ទាប់មកជ្រើសរើសប៊ូតុង **ស្នើសុំឥណទានពន្ធ**

៤. បំពេញព័ត៌មានដែលតម្រូវឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ

៥. ពិនិត្យ និងផ្ទៀងផ្ទាត់ រួចចុចបោះពុម្ព ពាក្យស្នើសុំ។

## III. ការដាក់ពាក្យស្នើសុំ

បន្ទាប់ពីបានបោះពុម្ពពាក្យស្នើសុំចេញពីប្រព័ន្ធរួច លោក-លោកស្រី ត្រូវដាក់ពាក្យស្នើសុំដោយភ្ជាប់ជាមួយនូវឯកសារតម្រូវគាំទ្រនានា ដែលមានបង្ហាញក្នុងពាក្យស្នើសុំ មកកាន់អគ្គនាយកដ្ឋានពន្ធដារ។ លោក-លោកស្រី នឹងទទួលបានលិខិតបញ្ជាក់ការទទួលឯកសារពីអគ្គនាយកដ្ឋានពន្ធដារ ដើម្បីរង់ចាំការឆ្លើយតប។ លោក-លោកស្រី អាចតាមដានដំណើរការនៃការឆ្លើយតបតាមរយៈកម្មវិធីលើទូរស័ព្ទ GDT Check and Track។

## IV. ការឆ្លើយតបលើការស្នើសុំ

លោក-លោកស្រី នឹងទទួលបានការឆ្លើយតបពីអគ្គនាយកដ្ឋានពន្ធដារ ដោយបោះពុម្ពលិខិតជូនដំណឹងស្តីពីការបញ្ជាក់ឥណទានពន្ធ ចេញពីប្រព័ន្ធអនឡាញដែលស្នើសុំ ឬអញ្ជើញមកទទួលដោយផ្ទាល់ពីនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃអគ្គនាយកដ្ឋានពន្ធដារ។

*ដើម្បីឈ្វេងយល់បន្ថែមអំពីការប្រើប្រាស់មុខងារស្នើសុំឥណទានពន្ធនេះ អ្នកប្រើប្រាស់អាចពិនិត្យមើលលម្អិតក្នុងសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការស្នើសុំចៀសវាងការយកពន្ធត្រួតគ្នាតាមអនឡាញ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលមាននៅលើគេហទំព័រ https://www.tax.gov.kh ឬអាចទូរស័ព្ទមក Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។*

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករសហគ្រាសទាំងអស់ នឹងចូលរួមអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យបានត្រឹមត្រូវ និងទទួលបានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

*Unofficial translation by TAFTAC*

**Kingdom of Cambodia**
**Nation Religion King**

**Ministry of Economy and Finance**
**General Department of Taxation**
No: 30856 GDT

Phnom Penh, 19 December 2022

# Instruction
# On
# Launch of Function of Application for Tax Credit in the Application Management System to Avoid Double Taxation via Online

The General Department of Taxation of the Ministry of Economy and Finance would like to inform all directors, managers or owners of enterprises that to implement Instruction 4084 GDT dated 26 March 2018 on Rules and Procedures for Implementation of Agreement to Avoid Double Taxation and to Prevent Tax Fraud Related to Income Tax (Double Taxation Agreement-DTA), and especially to modernize the tax administration, the General Department of Taxation has launched an application management system to avoid double taxation via online. Recently, the General Department of Taxation has developed an additional function to apply for tax credit in the application management system to avoid double taxation via online to help facilitate the application as well as to ensure effectiveness, transparency and accountability.

To log in to use the function of application for tax credit, you have to follow the rules and procedures below:

## I. Registration to use the system

For users who have not had an account, they have to register to use the system as follows:

1. Go to the website https://www.tax.gov.kh/km/e-service
2. Click on Create New Account button.
3. Complete the required information as shown in the system and then click on Next.

However, users who have already hand an account to use other online systems of the General Department of Taxation are not required to re-register.

## II. Detailed function for use of the system

In using the function of application for tax credit via the application management system to avoid double taxation, users have to follow the detailed procedure below:

1. Go to the website https://www.tax.gov.kh/km/e-service.
2. Use Username and Password to log in to use the system of the General Department of Taxation
3. Choose **Application Management System to Avoid Double Taxation** and then choose **Application for Tax Credit** button.
4. Complete the required information properly.
5. Check and verify and then click on **Print the Application Form**.

## III. Submission of Application Form

After printing the Application Form from the system, you have to submit the Application Form by attaching supporting documents as shown in the Application Form to the General Department of Taxation. You will receive a letter confirming the receipt of the documents from the General Department of Taxation to wait for a response. You can follow up the process of response by using GDT Check and Track phone app.

**IV. Response to the application**

You will receive a response from the General Department of Taxation by printing a letter on notice of tax credit confirmation from the online system or come to collect it directly from the Department of Law, Tax Policy and International Tax Cooperation of the General Department of Taxation.

*To find out more about the use of this Tax Credit Application, the user can see it in detail in the Manual on Use of Application Management System to Avoid Double Taxation via Online of the General Department of Taxation which is available on the website www.tax.gov.kh or call Call Center 1277 or chat in GDT Live Chat which can be downloaded via App Store for iOS or Play Store for Android.*

The General Department of Taxation of the Ministry of Economy and Finance strongly hopes that all directors, managers or owners of enterprises will participate in implementing this Instruction in a proper and highly effective manner.

**Minister attached to the Prime Minister**
**Delegate of Royal Government**
**In charge as Director General of General Department of Taxation**
(signed and stamped)
**Kong Vibol**

TAFTAC



សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា Textile, Apparel, Footwear & Travel Goods Association in Cambodia 柬埔寨纺织服装制鞋箱包协会
តំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុបភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ១២០៩០៦
Royal Group Phnom Penh Special Economic Zone, Phum Trapeang Kul, Sangkat Kantaok, Khan Kamboul, Phnom Penh, Cambodia. 120906
Tel: (855) 23 301 181 | E-mail: info@taftac-cambodia.org | Website: www.taftac-cambodia.org